## រឿងទី៣៖ ព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម

**ខគម្ពីរ៖ ម៉ាកុស១១:១០**

សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះរាជ្យ ដែលកំពុងតែមកដល់ គឺព្រះរាជ្យរបស់ព្រះបាទដាវីឌ ជាបិតារបស់យើង! ជយោ! ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត!»

ពិធីបុណ្យចម្លងនៅអ៊ីស្រាអែល បានឈានចូលមកដល់។

បុណ្យចម្លង គឺជាថ្ងៃដែលរំលឹកពីព្រះជាម្ចាស់បានជួយសង្គ្រោះប្រជាជនអ៊ីស្រាអែលពីអេស៊ីបមក តាមរយៈលោកម៉ូសេ។

ពេលដល់ថ្ងៃបុណ្យចម្លងម្តងៗ មនុស្សទាំងអស់តែងមកជួបជុំគ្នានៅព្រះវិហារ នៅក្រុងយេរូសាឡឹម។

មនុស្សជាច្រើនបានឡើងមកយេរូសាឡឹមដើម្បីធ្វើបុណ្យចម្លង។ ព្រះយេស៊ូក៏បានយាងមកយេរូសាឡឹមដែរ តែទ្រង់យាងមកដោយមូលហេតុផ្សេងគ្នា។

ព្រះយេស៊ូមានព្រះបន្ទូលទៅសាវ័កថា៖ «ចូរទៅភូមិនៅមុខអ្នករាល់គ្នា ពេលទៅដល់ភ្លាម អ្នកនឹងឃើញកូនលាមួយដែលគេចងទុក។ ចូរស្រាយវាដឹកមក។ ប្រសិនបើមានគេសួរថា "ហេតុអ្វីបានជាអ្នកស្រាយវា" ចូរឆ្លើយប្រាប់គេថា "ព្រះអម្ចាស់ត្រូវការវា"»។

ពួកសិស្សដឹកកូនលាមក យកអាវរបស់ខ្លួនក្រាលពីលើខ្នងកូនលា ព្រះអង្គក៏ឡើងគង់លើខ្នងកូនលានោះ។

ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏ខ្ពស់បំផុត ទ្រង់បានយាងទៅយេរូសាឡឹមដោយសុភាព ហើយបន្ទាបខ្លួន។

មនុស្សជាច្រើនបានលើកស្លឹកឈើឡើង ហើយស្រែកថា៖ «ហូសាណា! ព្រះយេស៊ូស្តេចពូជដាវីឌ! សូមសង្គ្រោះយើងខ្ញុំផង»

មនុស្សយ៉ាងច្រើន បានទទួលព្រះយេស៊ូដែលគង់លើខ្នងកូនលា ដោយដោះសំលៀកបំពាក់ខ្លួន ក្រាលនៅលើដីថ្វាយទ្រង់យាងកាត់ ស្រែកថា៖ «ហូសាណា ព្រះដ៏ខ្ពស់បំផុត»

មនុស្សម្នាទទួលព្រះយេស៊ូដូចជាស្តេច។ ពួកសាវ័កក៏មានមោទនភាពដែរ។ ប៉ុន្តែព្រះយេស៊ូជ្រាបយ៉ាងច្បាស់ថា សំឡេងជយឃោសនោះមិនបានយូរនោះឡើយ។

ព្រះយេស៊ូបានគិតអំពីព្រះរាជ្យព្រះជាម្ចាស់ មិនមែនដើម្បីទទួលសិរីរុងរឿងឡើយ។ ព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹមដើម្បីរងទុក្ខវេទនានៅលើឈើឆ្កាងជំនួសមនុស្សបាប។

ព្រះយេស៊ូទតមើលជុំវិញក្រុងយេរូសាឡឹម ហើយយាងចូលទៅក្នុងព្រះវិហារ។

ពេលចូលក្នុងព្រះវិហារ ព្រះយេស៊ូភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយឃើញព្រះវិហារពេញដោយការរកស៊ីលក់ដូរ។

ព្រះយេស៊ូក្រោធ ហើយមានព្រះបន្ទូលទៅគេថា៖ «ដំណាក់របស់យើងត្រូវធ្វើជាកន្លែងសម្រាប់អធិស្ឋាន តែអ្នករាល់គ្នាបែរជាយកធ្វើជាសំបុកចោរទៅវិញ»

ព្រះយេស៊ូបានបណ្តេញពួកអ្នកលក់ដូរទាំងអស់ចេញពីព្រះវិហារ។

ចំណែកខាងពួកក្រុមនាយកបូជាចារ្យ និងអាចារ្យ កាលបានដឹងរឿងនេះហើយ ពួកគេមានការទាស់ចិត្ត និងខ្លាចព្រះយេស៊ូជាខ្លាំង។

ពីព្រោះមានមនុស្សជាច្រើនកំពុងធ្វើតាមការបង្រៀនរបស់ព្រះយេស៊ូ។

ពួកគេគិតថា ការបកស្រាយនិងប្រកាសពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺមានតែពួកអ្នកដែលខ្ពង់ខ្ពស់ដូចជាពួកខ្លួន ប៉ុណ្ណោះ ទើបអាចធ្វើបាន។



**សកម្មភាពទី១** សូមឆ្លើយនិងសំណួរខាងក្រោម។

a. តើនៅក្នុងក្រុងយេរូសាឡឹមមានរៀបចំពិធីអ្វី?

------------------------------------------------------------------------

b. តើសាវករបស់ព្រះយេស៊ូ បាននាំសត្វអ្វីមក?

------------------------------------------------------------------------

c. តើបណ្ដាជនបានមកទទួលព្រះយេស៊ូយ៉ាងដូចម្ដេច នៅពេលទ្រង់យាងចូលក្នុងក្រុងយេរូសាឡឹម?

------------------------------------------------------------------------

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញឱ្យចាំ(ម៉ាកុស១១:១០)

**សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះរាជ្យដែលកំពុងតែមកដល់ គឺព្រះរាជ្យរបស់ព្រះបាទដាវីឌ ជាបិតារបស់យើង!**
**ជយោ! ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត៕**

**សកម្មភាពទី២** សូមស្វែងរករូបភាពខុសៗគ្នាចំនួនប្រាំ ក្នុងរូបភាពខាងក្រោម។



